# ព្រឹត្តិបត្រព័ត៌មាន

## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាប( ធី.អេស.អេស.ឌី )

*ផ្តល់ថវិកាអនុវត្តដោយៈ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា*

**គម្រោងទន្លេសាប ធី.អេស.អេស.ឌីៈ** ជួយកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ប្រមាណជា ៦៣ម៉ឺនគ្រួសារ ក្នុង១៩៦ឃុំ ២៨ស្រុក ក្នុងខេត្ត បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និង ត្បូងឃ្មុំ តាមរយៈ (១) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដល់ផលិតភាពកសិកម្ម (២)ការបង្កើនសមត្ថភាពបច្ចេកទេសរបស់កសិករខ្នាតតូច (៣) ការផលិត-ផ្គត់ផ្គង់ពូជដំណាំមានគុណភាព និង (៤) ការផ្តល់ព័ត៌មានដល់កសិករ។

## មាតិកាសម្រាប់ត្រីមាសទី ៤ ឆ្នាំ ២០១៤


១. ក្រុមកែលម្អជីវភាព ផ្តល់ប្រយោជន៍សេដ្ឋកិច្ច និង សង្គម (ដោយ KPC/TBK-LICA)

២. ទុនបង្វិលក្រុម ជួយពង្រីកប្រភពចំណូលគ្រួសារ តាមរយៈការកែលម្អផលិតភាពសិប្បកម្មត្បាញក្រម៉ាតាមគ្រួសារ (ដោយ KPC/TBK-LICA)

៣. ទុនបង្វិលក្រុម ជួយចម្លងគ្រួសារខ្ញុំ ឲ្យមានជីវភាពប្រសើរឡើង (ដោយ SRP-LICA)

៤. ការសាយភាយបច្ចេកវិទ្យាដាំបន្លែ និង កែលម្អសង្វាក់ទីផ្សារបន្លែ (ដោយ KPC/TBK-PAEA )

៥. ដាំបន្លែតាមបច្ចេកទេសថ្មី បានចំណេញទ្វេដង (ដោយ BMC-PAEA )

៦. បង្កើនប្រាក់ចំណូល តាមរយៈការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ (ដោយ SRP-PAEA )

៧. ខ្ញុំរៀនតាមការមើលវីដេអូ ងាយស្រួលយល់ និងឆាប់ចេះបច្ចេកទេសចិញ្ចឹមមាន់ (ដោយ KPT-LICA)


### ១. ក្រុមកែលម្អជីវភាព ផ្តល់ប្រយោជន៍សេដ្ឋកិច្ច និងសង្គម

មីង *ហ៊ុល រ៉េត* កសិករក្រប្រភេទ-២ នៅភូមិត្រពាំងស្មៀង ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បានចូលជាសមាជិកក្រុមកែលម្អជីវភាព (លីគ) ក្នុងឆ្នាំ ២០១៣។ គ្រួសារគាត់មានគ្នាបីនាក់ ប្តីគាត់ឈ្មោះ លោក *ហ៊ន់ ផល* និងកូនស្រី អាយុ១១ឆ្នាំ រៀនថ្នាក់ទី៥។ មុនចូលក្រុមលីគ ជីវភាពគ្រួសារមីង ពឹងលើការធ្វើស្រែ-ចំការ ដាំបន្លែជុំវិញផ្ទះ ហើយនៅពេលមានការងារធ្វើ ស៊ីឈ្នួលពលកម្មគេដើម្បីបានចំណូលបន្ថែម។ ជីវភាពគ្រួសាររបស់គាត់ ជួបការលំបាក ដោយសារមិនសូវមានរបរ ហើយមានពេលទំនេរច្រើន។ ប្តីគាត់មិនសូវបានជួយការងារគាត់ទេ ហើយបានចំណាយពេលវេលាដើរផឹកស៊ី និង សម្រាក មិនសូវអើពើជួយការងារគ្រួសារឡើយ។

ក្រោយពីចូលក្នុងក្រុមលីគមក មីងបានចូលរួមយ៉ាងសកម្មក្នុងការប្រជុំក្រុមក្នុងភូមិ និង ការបណ្តុះបណ្តាលបច្ចេកទេសមួយចំនួន ដូចជា ផលិតកម្មដំណាំស្រូវ បច្ចេកទេសដំណាំបន្លែ បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ និង បច្ចេកទេសចិញ្ចឹមមាន់។ ពេលខ្លះ ប្តីរបស់គាត់ក៏បានចូលរួមប្រជុំស្តាប់ការពន្យល់ណែនាំពីការងារក្រុមលីគ និង ការផ្សព្វផ្សាយផងដែរ។ នៅខែកក្កដា ឆ្នាំ ២០១៤ គ្រួសារគាត់បានខ្ចីប្រាក់ចំនួន ៤0ម៉ឺនរៀល ពីទុនបង្វិលក្រុមរបស់គាត់។

បន្ទាប់ពីទទួលបានចំណេះថ្មីៗ មីងបានរៀបចំចិញ្ចឹមមាន់ តាមបច្ចេកទេសដែលបានរៀន ដោយរៀបចំសាងសង់ទ្រុង មានហ៊ុំទីធ្លាព័ទ្ធជុំវិញ និង ខណ្ឌសំណាញ់ជាប្លុកៗ សម្រាប់ដាក់មាន់តាមអាយុ។ នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១៤ គាត់ទិញកូនមាន់ស្រុក អាយុ ២១ថ្ងៃ ដែលមានគុណភាពល្អ ចំនួន ១00ក្បាល ពីកសិដ្ឋានមួយក្នុងខេត្តកំពង់ចាម មកចិញ្ចឹម ដែលមានតម្លៃសរុបជាង ៤៧ម៉ឺនរៀល ដោយប្រើលុយខ្ចីពីក្រុម និង ប្រាក់សន្សំរបស់គាត់។ បូករួមទាំងការចំណាយទិញសម្ភារចាំបាច់សម្រាប់សាងសង់ទ្រុង និងសំណាញ់ព័ទ្ធទ្រុង ស្នូកទឹកចំណី និង ចំណីបន្ថែម គាត់បានចំណាយថវិកាសរុបជាង ៥៦ម៉ឺនរៀល សម្រាប់ចាប់ផ្តើមការចិញ្ចឹមមាន់នេះ។



មីងបានឲ្យដឹងថា *"រហូតមកដល់ចុងខែមករា ឆ្នាំ២០១៥នេះ ការចិញ្ចឹមមាន់របស់ខ្ញុំបានជិត៣ខែហើយ មាន់ខ្ញុំធំធាត់លឿន ជាងមាន់ចិញ្ចឹមលែងតាមទំលាប់។ ឥឡូវនេះ មាន់មានទម្ងន់ពី ១,២ ទៅ ១,៥គីឡូ ដោយសារការអនុវត្តតាមបច្ចេកទេសដែលខ្ញុំបានរៀន។ ខ្ញុំសប្បាយចិត្តណាស់ពេលចិញ្ចឹមមាន់ បានលទ្ធផលល្អ ធំធាត់លឿនបែបនេះ។ ខ្ញុំគ្រោងនឹងលក់មាន់ នៅពាក់កណ្តាលខែកុម្ភៈ មុនពេលចូលឆ្នាំចិនខាងមុខ ដើម្បីឲ្យបានតម្លៃខ្ពស់"* ។

ដោយមើលឃើញពីលទ្ធផលចិញ្ចឹមមាន់បានល្អបែបនេះ ឧស្សាហ៍មានសមាជិកក្រុមកែលម្អជីវភាព និង អ្នកភូមិមួយចំនួនបានមកមើល និង សាកសួរពីបច្ចេកទេស និង បទពិសោធន៍ចិញ្ចឹមមាន់របស់គាត់។

ក្រៅពីផលប្រយោជន៍សេដ្ឋកិច្ចគ្រួសារ មីងក៏បានប្រាប់ឲ្យដឹងពីការសំគាល់ឃើញការផ្លាស់ប្តូរទង្វើ/ឥរិយាបថរបស់ប្តីគាត់ មកចេះជួយការងាររបស់គាត់ខ្លះ ដែលខុសប្លែកពីមុន មិនសូវរវីរវល់ជួយការងារគ្រួសារ គិតតែដើរលេងជាមួយមិត្តភក្តិ ស៊ីផឹក និងរករឿងប្រពន្ធកូន។ ទាក់ទងនឹងរឿងនេះ លោក *ហ៊ាន់ ផល* បានប្រាប់ថា "*កាលពីមុន ខ្ញុំមិនសូវចេះជួយការងារផ្ទះគិតតែពីដើរលេងផឹកស្រា ពេលមកផ្ទះ រករឿង វាយធ្វើបាបប្រពន្ធកូន។ ប៉ុន្តែក្រោយពីចូលក្នុងក្រុមនេះមក ខ្ញុំបានជួយរំលែកការងារផ្ទះរបស់ប្រពន្ធ ដូចជា ជួយជម្រះស្មៅដំណាំ រៀបចំ និង សម្អាតទ្រុងមាន់ រកកណ្តៀរសម្រាប់ជាចំណីមាន់ និងជួយកិច្ចការផ្ទះមួយចំនួនទៀត ដែលនេះ គឺដោយសារមានការជួយប្រាប់ពីក្រុមគ្រួសារអ្នកជិតខាង និង ការពន្យល់របស់ភ្នាក់ងារអនុវត្តគម្រោង*"។

## ២. ទុនបង្វិលក្រុម ជួយពង្រីកប្រភពចំណូលគ្រួសារ តាមរយៈការកែលម្អផលិតភាពសិប្បកម្មត្បាញក្រម៉ាតាមគ្រួសារ

*ខុន សុខឃីម* ជាស្ត្រីមេម៉ាយ រស់នៅក្នុងភូមិល្វេលើ ឃុំល្វេ ស្រុកកោះសុទិន ខេត្តកំពង់ចាម សព្វថ្ងៃប្រកបរបរធ្វើស្រែ ចំការ និង ត្បាញក្រម៉ា នៅពេលទំនេរ ពិសេសនៅរដូវប្រាំង។ គ្រួសារគាត់ ជាគ្រួសារក្រប្រភេទ-២ មានសមាជិកបីនាក់ (កូន និង ម្តាយ) ហើយបានចូលជាសមាជិកក្រុមកែលម្អជីវភាព នៅខែតុលា ឆ្នាំ២០១៣ ។



កំពុងអង្គុយរៀបចំកីតម្បាញបណ្តើរ និងត្បាញក្រម៉ាបណ្តើរ បងស្រីបានមានប្រសាសន៍ថា បន្ទាប់ពីបានចូលក្រុមលីគមក នៅខែកក្កដា ឆ្នាំ២០១៤ គាត់បានខ្ចីប្រាក់ពីក្រុមចំនួន ៤០ម៉ឺនរៀល សម្រាប់ត្បាញក្រម៉ា។ គាត់បានយកប្រាក់ចំនួន ៣០ម៉ឺនរៀល ទៅទិញអំបោះ និង ១០ម៉ឺនទៀត ទៅជួសជុលកីតម្បាញ។ បងស្រីបានបន្ថែម ក្នុងអំបោះមួយកីនេះ គាត់ប្រើពេលត្បាញ ១ខែ បាន១០០ ក្រម៉ា (ធំ ៥៥ និង តូច ៤៥)។ ក្រម៉ាដែលត្បាញបាន មានគេមកទិញដល់ផ្ទះ លក់បានតម្លៃ ៥.០០០រៀល សម្រាប់ក្រម៉ាតូច និង ៦.៥០០រៀល សម្រាប់ក្រម៉ាធំ។ ក្នុងមួយសារៗ គាត់អាចរកបានចំណូលពី ៥០ ទៅ ៦០ម៉ឺន ក្នុងនោះ បានចំណេញ (មិនទាន់គិតពលកម្ម) ប្រមាណពី ១៨ ទៅ ២០ម៉ឺនរៀល។

គាត់បានបញ្ជាក់ថាប្រាក់ចំណេញបានពីការត្បាញក្រម៉ានេះ មួយចំនួនសម្រាប់ផ្គត់ផ្គង់គ្រួសារ ហើយមួយចំនួនទៀតសម្រាប់ផ្គត់ផ្គង់កូនរៀន។ បងស្រីបានមានប្រសាសន៍បន្ថែមថា "*គ្រួសារខ្ញុំ មានជីវភាពប្រសើរជាងមុន បន្ទាប់ពីបានចូលជាសមាជិកក្រុមកែលម្អជីវភាពភូមិនេះមក ហើយខ្ញុំសូមថ្លែងអំណរគុណដល់គម្រោងដែលបានជួយគាំទ្រគ្រួសារខ្ញុំ*"។

## ៣. ទុនបង្វិលក្រុម ជួយចម្លងគ្រួសារខ្ញុំ ឲ្យមានជីវភាពប្រសើរឡើង

មីង *ញ៉ែម ចំប៉ី* ជាមេគ្រួសារក្រប្រភេទ-១ មានប្តីពិការ និង កូនចំនួន៧នាក់ រស់នៅក្នុងភូមិស្រះស្រង់ត្បូង សង្កាត់នគរធំ ក្រុងសៀមរាប។ ជីវភាពគ្រួសារប្រចាំថ្ងៃរបស់គាត់ ពឹងលើការធ្វើនំលក់ (អន្សមខ្ទុរ/ចេក/ល្ពៅ អាកោត្នោត ចេកចៀន ពងអន្សង) ធ្វើស្រែ ដាំបន្លែ/ដំណាំរួមផ្សំ និងចិញ្ចឹមសត្វបន្តិចបន្តួច ហើយបានចំណូល (ប្រមាណ ៧៥ម៉ឺនរៀលក្នុង១ខែ) ត្រឹមតែគ្រប់គ្រាន់ សម្រាប់ចំណាយចាំបាច់ប្រចាំថ្ងៃរបស់គ្រួសារ (ព្យាបាលជម្ងឺប្តីលើសឈាមពិការ ការសិក្សារបស់កូន៥នាក់ ចំណាយលើអគ្គិសនី សម្ភារប្រើប្រាស់ និង ម្ហូបអាហារ)។



ក្នុងឆ្នាំ២០១៤ គ្រួសារគាត់ បានចូលក្នុងក្រុមកែលម្អជីវភាព ភូមិស្រះស្រង់ត្បូង ហើយគាត់ត្រូវបានជ្រើសរើសធ្វើជាអនុប្រធានក្រុម ហើយនៅខែកក្កដា ឆ្នាំ ២០១៤ បានខ្ចីប្រាក់ចំនួន៨០ម៉ឺនរៀល (សមាជិកក្រុមម្នាក់ទៀត មិនបានខ្ចី) ពីទុនបង្វិលក្រុម។ គាត់បានប្រើប្រាក់កម្ចីនេះ សម្រាប់ពង្រឹងមុខរបរគ្រួសារគាត់បន្ថែមទៀត ដោយទិញមាន់មេចំនួន៧ក្បាល (បន្ថែមលើមេមានស្រាប់ចំនួន ១៣ក្បាល) ហើយពង្រីកទ្រុងបន្ថែម និង ទិញឆ្នាំងធំចំនួន៣ (បន្ថែមលើឆ្នាំងមានស្រាប់មួយ) សម្រាប់ធ្វើនំលក់។ ការបង្កើនឆ្នាំងធ្វើនំនេះ អាចជួយឲ្យគាត់បង្កើនចំនួននំលក់ ទៅតាមការបញ្ជាទិញរបស់គេ ហើយបានចំណេញជាមធ្យម ៨ម៉ឺនរៀលក្នុងមួយថ្ងៃៗ។ សម្រាប់ការចិញ្ចឹមមាន់ មកដល់ដើមឆ្នាំ២០១៥នេះ គាត់បានលក់ចំនួន៣លើករួចហើយ ហើយបានប្រាក់សរុបប្រមាណជា ៤០ម៉ឺនរៀល។ ទន្ទឹមគ្នានេះផងដែរ ក្នុងរយៈពេលបីខែចុងឆ្នាំ២០១៤នេះ គាត់ក៏បានលក់ដំណាំរួមផ្សំ/បន្លែជុំវិញផ្ទះ បានប្រាក់សរុប ជាង១លានរៀលផងដែរ។ ចំណូលកើនឡើងថ្មីនេះ បានជួយសម្រួលឲ្យកូនរបស់គាត់បានរៀនចប់ ហើយទទួលបានការងារធ្វើពីខែតុលាមក ចំនួន៤នាក់ ដែលអាចទទួលបានប្រាក់ខែសរុបចំនួន ៥៨០ដុល្លារ ក្នុងមួយខែៗ។



បច្ចុប្បន្ន គ្រួសាររបស់គាត់មានជីវភាពប្រសើរជាងមុនច្រើន។ ក្រៅពីពង្រីកមុខរបរ គាត់បានជួសជុលកែលម្អផ្ទះរបស់គាត់។ មិនតែប៉ុណ្ណោះ គាត់បានទិញដីជាប់ផ្ទះមួយកន្លែង ទំហំ២០x៥០ម៉ែត្រ សព្វថ្ងៃសងគេជិតរួចហើយ។ គាត់បាននិយាយថា "*ខ្ញុំសប្បាយចិត្តណាស់ដែលបានចូលក្នុងក្រុមកែលម្អជីវភាពនេះ ហើយ នឹងខិតខំបន្ថែមទៀត ដើម្បីលើកស្ទួយជីវភាពគ្រួសារខ្ញុំ ឲ្យកាន់តែប្រសើរឡើង*"។



## ៤. ការសាយភាយបច្ចេកវិទ្យាដាំបន្លែ និង កែលម្អសង្វាក់ទីផ្សារបន្លែ

ភូមិខ្សាក ស្ថិតក្នុងឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ត្រូវបានជ្រើសរើសជាភូមិគោលដៅគម្រោង និង ជាភូមិដែលមានសក្តានុពលខ្លាំងសម្រាប់ដាំដំណាំបន្លែបានពេញមួយឆ្នាំ ដោយសារ មានទឹកចេញខួបប្រាំងខួបវស្សា។ ចុងឆ្នាំ ២០១៣ ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុកពញាក្រែក បានធ្វើបង្ហាញបច្ចេកវិទ្យាដំណាំបន្លែ (ម្រះ) ប្រើប្រព័ន្ធដំណក់ទឹក(ឌ្រីប) លើដីចំការរបស់បងស្រី *ហយ ភ័ណ្ឌ* ជាប្រធានក្រុមកែលម្អជីវភាព (លីគ) លើផ្ទៃដី ៧០០ ម៉ែត្រការ៉េ។ ក្នុងរយៈពេល៣ខែ នៃការដាំបង្ហាញដំណាំម្រះ គាត់បេះផលផ្លែម្រះបានជាង ១.៤០០គីឡូក្រាម ហើយលក់បានប្រាក់ ២លាន ៣សែនរៀល ក្នុងនោះចំណេញបានជាង ១លាន ៣សែនរៀល។ បន្ទាប់ពីដំណាំម្រះ គាត់បានបន្តប្រើបច្ចេកវិទ្យានេះដាំបន្លែផ្សេង លើទីតាំងដដែលបានចំនួនបួនដង ដែលលើកទី២ ដាំសណ្តែកកួរ លើកទី៣បី ដាំម្រះ (លាយស្ពៃ តាមចន្លោះរងម្រះ) និងលើកទី៤ កំពុងដាំសណ្តែកកួរ។



នៅពាក់កណ្តាលឆ្នាំ ២០១៤នេះ ដោយកសិករក្នុងមូលដ្ឋានមានចំណាប់អារម្មណ៍ខ្លាំងលើការដាំដំណាំបន្លែ ពិសេសម្រះ និងក្នុងគោលបំណងជំរុញការផលិតបន្លែមានគុណភាព និងសុវត្ថិភាព ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក បានកៀងគរកសិករមកពីភូមិជិតខាងចំនួន៣ ភូមិ ក្នុងឃុំពពេល មកចូលរួមក្នុងសាលារៀនចំការកសិករស្តីពី ការអនុវត្តកសិកម្មល្អ និង បានធ្វើការបង្ហាញបច្ចេកវិទ្យាដាំដំណាំបន្លែ(ម្រះ) លើចំការរបស់បងស្រី *យឿង ចរ្យិត* លើផ្ទៃដី ៦០០ម៉ែត្រការ៉េ ។ សាលារៀនចំការកសិករបន្លែនេះ បានប្រព្រឹត្តទៅរយៈពេល ១០សប្តាហ៍ បង្រៀនកសិករជាង២០នាក់ ឲ្យអនុវត្តជាក់ស្តែងផ្ទាល់ តាមជំហ៊ានសំខាន់ៗនៃបច្ចេកទេសដាំដំណាំម្រះ តាមគោលការណ៍អនុវត្តកសិកម្មល្អ ដើម្បីទទួលបានបន្លែមានគុណភាព និង សុវត្ថិភាពចំណីអាហារ។ ក្រោយពីបញ្ចប់សាលារៀននេះភ្លាម មានកសិករ ៧នាក់ (ស្ត្រី ២នាក់) ក្នុងនោះមានសមាជិកក្រុមលីគ ចំនួន៤នាក់ បានកាប់ឆ្ការពង្រីកផ្ទៃដីដាំបន្លែរបស់ពួកគាត់ ដោយដាំដំណាំម្រះ សណ្តែកកួរ ននោង និង ស្ពៃ។ បន្ទាប់ពីឃើញសកម្មភាពផុលផុសដាំបន្លែបានផលរបស់កសិករក្នុងភូមិនោះ មានអ្នកប្រមូលទិញបន្លែក្នុងភូមិម្នាក់ ក៏បានអនុវត្តតាមនេះដែរ។



កសិករ *ហយ ភ័ណ្ឌ* បានឲ្យដឹងថា ការលក់បន្លែផ្លែម្រះដំបូង នៅផ្សារស្ទឹង(ក្នុងឃុំពពេល) មានជួបការលំបាកខ្លះ ដោយអ្នកទិញបានបង្អាប់បន្លែរបស់គាត់ថា ជាបន្លែនាំចូលពីវៀតណាម ហើយឲ្យតម្លៃទាប។ បន្ទាប់ពីទទួលបានព័ត៌មាននេះ ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក បានរៀបចំធ្វើជាខិត្តប័ណ្ណផ្សព្វផ្សាយព័ត៌មាន ដោយមានដាក់រូបថតចំការម្រះ និងម្ចាស់ចំការ នៅក្នុងខិតប័ណ្ណ ហើយចែក និងបិទផ្សាយតាមទីសាធារណៈក្បែរៗផ្សារ។ ចាប់ពីពេលនោះមក ទើបអ្នកទិញ ចាប់ផ្តើមជឿថាជាបន្លែរបស់កសិករខ្មែរ ដាំក្នុងឃុំពពេល ហើយអាចលក់បានតម្លៃថ្លៃជាង បន្លែនាំចូល។



បច្ចុប្បន្នផលិតផលបន្លែរបស់កសិករនៅភូមិនេះមានទីផ្សារល្អ ប៉ុន្តែនៅមិនទាន់មានបន្លែសម្រាប់ផ្គត់ផ្គង់បានគ្រប់គ្រាន់ គ្រប់ពេលនៅឡើយទេ។ ដូច្នេះ ដើម្បីឲ្យមានបន្លែគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់នៅលើទីផ្សារ ក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុកពញាក្រែក កំពុងផ្សព្វផ្សាយបន្ត ជំរុញក្រុមកសិករឲ្យពង្រីកផ្ទៃដីដាំដុះ និង ពង្រីកសមាជិកថ្មីបន្ថែមទៀត។ ក្នុងឆ្នាំ២០១៥នេះ ដើម្បីឲ្យការផលិតបន្លែរបស់គាត់ កាន់តែមានគុណភាព និង ឆ្លើយតបបានតាមតម្រូវការទីផ្សារ ក្រុមកសិករដាំបន្លែក្នុងភូមិខ្សាកនេះ នឹងទទួលបានការគាំទ្រថែមទៀត ទាំងផ្នែកបច្ចេកទេសផលិតបន្លែឲ្យមានសុវត្ថិភាព ដោយមានការបញ្ជាក់ទទួលស្គាល់ផលិតផលផលិតតាមគោលការណ៍អនុវត្តកសិកម្មល្អ និង ផ្នែកទីផ្សារ។

## ៥. ដាំបន្លែតាមបច្ចេកទេសថ្មី បានចំណេញទ្វេដង

មីង *ដាំ សាខន* អាយុ៥៦ឆ្នាំ ជាស្ត្រីមេម៉ាយ និងជាមេគ្រួសារ រស់នៅភូមិ ដីឡូតិ៍ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ គ្រួសាររបស់គាត់ មានគ្នា៣នាក់ (ស្ត្រី ១នាក់)។ គាត់មានដីស្រែ ២ហិកតា និង ដីក្រោយលំនៅដ្ឋានសម្រាប់ដាំបន្លែ និងដំណាំរួមផ្សំ ដូចជា ល្ពៅ សណ្តែកកួរ ត្រកួន ស្ពៃ ផ្ទី ត្រាវជាដើម។ ការដាំដំណាំរបស់គាត់ទទួលបានផលតិច ដោយសារតែគាត់ធ្វើតាមទំលាប់ រៀន/ចេះតៗគ្នាមក។ កន្លងមក សណ្តែកកួរ ដាំតាមទំលាប់ លើផ្ទៃដី ៣០០ម៉ែត្រការ៉េ បានផលប្រមាណ ១៨០គីឡូ ហើយប្រមូលផលបានត្រឹមតែ១៥ថ្ងៃប៉ុណ្ណោះ។ គាត់លក់ទទួលបានចំណូលប្រមាណជា ២២ម៉ឺនរៀល ក្នុងនោះចំណាយអស់ ១៥ម៉ឺនរៀល (មិនទាន់គិតពីកំលាំងពលកម្ម)។



រដូវវស្សាឆ្នាំ២០១៤ គាត់បានចូលរួមជាមួយគម្រោង ធ្វើបង្ហាញបច្ចេកទេសដាំសណ្តែកកួរ លើផ្ទៃដី ៣០០ម៉ែត្រការ៉េ ដោយប្រើពូជកូនកាត់ ដាក់ជីតាមបច្ចេកទេស (បរិមាណ និង ពេលវេលា) និងប្រើប្រពន្ធ័ដំណក់ទឹកសម្រាប់ស្រោចស្រព ព្រមទាំងថែទាំដំណាំតាមបច្ចេកទេស។ បន្ទាប់ពីបានអនុវត្តតាមការណែនាំបច្ចេកទេស ដែលផ្តល់ដោយក្រុមគាំទ្របច្ចេកទេសកសិកម្មក្រុងសិរីសោភ័ណ្ឌ មួយរដូវមក គាត់បេះបានសណ្តែកកួរចំនួន ៤៦០គីឡូ លក់បានតម្លៃ ១.៣០០រៀលក្នុង១គីឡូ ហើយបានប្រាក់សរុបចំនួន ៥៥ម៉ឺនពីរពាន់រៀល។ ក្នុងការដាំសណ្តែកតាមបច្ចេកទេសនេះ គាត់បានចំណាយសរុប (គិតទាំងពលកម្មរបស់គាត់) ប្រមាណជា ៣៥ម៉ឺនរៀល ហើយបន្ទាប់ពីទូទាត់រួចគាត់នៅសល់ប្រាក់ចំណេញប្រមាណជា ២០ម៉ឺនរៀល។

### ៦. បង្កើនប្រាក់ចំណូល តាមរយៈការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

កសិករ *ណយ នាត* ភេទស្រី អាយុ៤៥ឆ្នាំ រស់នៅក្នុងភូមិ អញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ ប្ដីឈ្មោះ *ជុំ សំ* អាយុ ៥០ឆ្នាំ ជាកម្មករសំណង់ មានកូន៤នាក់ (ស្រី២នាក់) នៅរៀន។ គ្រួសារគាត់មានជីវភាពខ្វះខាត ដោយពឹងលើការងារកសិកម្មរួមផ្សំលើផ្ទៃដីតូច (២.០០០ម៉ែត្រការ៉េ) និងលក់កំលាំងពលកម្មប្រចាំថ្ងៃ។



ដោយសារការព្យាយាម និងការប្ដេជ្ញាចិត្តរបស់គាត់ ក្រុមគាំទ្របច្ចេកទេសកសិកម្មក្រុងសៀមរាប បានជ្រើសរើសគាត់ ជាកសិករធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមជ្រូកសាច់ ក្នុងឆ្នាំ២០១៤។ គាត់បានទទួលការគាំទ្របច្ចេកទេសចិញ្ចឹមសត្វ ពូជ សម្ភារសាងសង់ទ្រុង ចំណីផ្សំ និងចាក់ថ្នាំបង្ការ ព្រមទាំងការណែនាំបច្ចេកទេសយ៉ាងជាប់លាប់ពីក្រុមការងារគម្រោង។ រយៈពេលត្រឹម ៤ខែ នៃការអនុវត្តតាមបច្ចេកទេសបង្ហាញ ជ្រូករបស់គាត់បានលូតលាស់រហូតដល់ ១០០គីឡូក្រាម។ គាត់បានលក់ជ្រូក ១ក្បាល ទទួលបានប្រាក់ ១លានរៀល។ តាមការវិភាគសេដ្ឋកិច្ច (ដោយមិនគិតថ្លៃរំលស់ទ្រុង) គាត់ទទួលបានប្រាក់ចំណេញប្រហែល ៣២ម៉ឺនក្នុងជ្រូក១ក្បាល។ ក្រៅពីដកប្រើខ្លះសម្រាប់តម្រូវការរបស់គ្រួសារ គាត់បានយកប្រាក់លក់ជ្រូកបាន ទៅទិញកូនជ្រូក ២ក្បាល និងចំណីផ្សំមួយចំនួនផងដើម្បីពង្រីកការចិញ្ចឹមជ្រូកសាច់ និងជ្រូកមេយកកូនផង។

មីង *ណយ នាត* បានរំលឹកថា គម្រោង តាមរយៈក្រុមគាំទ្របច្ចេកទេសកសិកម្មស្រុក បានផ្ដល់នូវចំណេះដឹងថ្មី និងបទពិសោធន៍ល្អៗ ក្នុងការគ្រប់គ្រងការចិញ្ចឹមសត្វរបស់គាត់ ឲ្យបានជោគជ័យ អាចរកប្រាក់ចំណូលបន្ថែម ជួយឲ្យគ្រួសារគាត់ដោះស្រាយជីវភាពបានទាន់ពេល។ គាត់សន្យាថា នឹងធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍ ទទួលបានពីគម្រោង ជាមួយកសិករដទៃទៀត ដែលមានចំណាប់អារម្មណ៍ដូចគាត់។

### ៧. ខ្ញុំរៀនតាមការមើលវីដេអូ ងាយស្រួលយល់ និងឆាប់ចេះបច្ចេកទេសចិញ្ចឹមមាន់

ប្រជាជនក្រីក្រជនបទភាគច្រើន ប្រកបរបរកសិកម្ម និងមិនសូវចេះអក្សរ។ ការរៀនសូត្រពីបច្ចេកទេសកសិកម្ម ក៏មិនសូវទទួលបានផល តាមបំណងរបស់គាត់ដែរ ដោយសារវិធីបណ្ដុះបណ្ដាល ផ្ដោតជាចំបងលើការសរសេរអក្សរ និងតម្រូវឲ្យអានច្រើន។ ដូច្នេះ ការរៀនតាមការរយៈការមើលរូបភាពវីដេអូ ដោយមានការពន្យល់ខ្លះៗនោះ គឺជា វិធីសាស្ត្រដែលសមស្រប និងគួរឲ្យទាក់ទាញខ្លាំងសម្រាប់កសិករ។



ជាក់ស្ដែងពូ *ពៅ មឿន* អាយុ ៣៩ឆ្នាំ មានភរិយាឈ្មោះ *យុត សារ៉េន* មានកូន ៣នាក់ ជាប្រធានក្រុមកែលម្អជីវភាព (លីគ) ក្នុងភូមិឈើទាលជ្រុំ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បានរៀនបច្ចេកទេសចិញ្ចឹមមាន់ តាមរយៈមើលខ្សែវីដេអូ (ថតដាក់បង្ហាញក្នុងឧបករណ៍ *ថេបប្លែត*) ដែលបានបញ្ចាំងឲ្យមើលជារឿយៗ ដោយអ្នកផ្សព្វផ្សាយឃុំ។ ក្រៅពីបច្ចេកទេសចិញ្ចឹមមាន់ គាត់ក៏បានរៀនពីបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ តាមរយៈការមើលវីដេអូនេះ ហើយក៏បានយកវាទៅប្រើផងដែរ។

បន្ទាប់ពីបានចូលរួមជាមួយក្រុមលីគ នៅដើមខែមេសា ឆ្នាំ២០១៤ មក គាត់បានខ្ចីថវិកាពីក្រុមចំនួន ៤០ម៉ឺនរៀល ដើម្បីរៀបចំទ្រុងមាន់ ធ្វើទ្រុងផ្សាំកូនមាន់ និងទិញមេមាន់បន្ថែមទៀត ដើម្បីចិញ្ចឹម។ គាត់បានធ្វើទ្រុងតាមបច្ចេកទេស ចាក់ថ្នាំបង្ការមាន់របស់គាត់ ថែរក្សាមាន់ធំ និងកូនមាន់ និង ផ្សំចំណីទៅតាមការណែនាំ ដែលមានបង្ហាញនៅក្នុងខ្សែវីដេអូ។

គាត់បានមានប្រសាសន៍ថា "*ការមើលវីដេអូបច្ចេកទេសកសិកម្មពីថេបប្លែតនេះ មានលក្ខណៈងាយស្រួលយល់ រហ័សចាប់បាន ដោយសារវាមានរូបភាពបង្ហាញផ្ទាល់ជាក់ស្ដែង និងមានសំលេងពន្យល់ រួមផ្សំនឹងការពន្យល់បន្ថែមលើចំណុចខ្លះៗ ពីអ្នកផ្សព្វផ្សាយឃុំ។ កាលពីមិនទាន់បានរៀនបច្ចេកទេសចិញ្ចឹមមាន់ ខ្ញុំចិញ្ចឹមមាន់តិចតួច ហើយកូនមាន់ញាស់មក មិនសូវបានគង់ទេ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមានទំនុកចិត្ត ហើយអាចចិញ្ចឹមបានល្អជាងមុនច្រើន*"។



គាត់បានទិញមេមាន់ ១០បន្ថែម កែសម្រួលទ្រុងមាន់ ធ្វើស្នូកទឹកស្នូកចំណី ដាក់សំណាញ់ហ៊ុំព័ទ្ធទ្រុង និងធ្វើទ្រុងចល័តសម្រាប់ផ្សាំកូនមាន់។ មកដល់ចុងឆ្នាំ ២០១៤ នេះ ការចិញ្ចឹមមាន់របស់គាត់ បានរីកចម្រើនយ៉ាងខ្លាំង មាន់ធំធាត់លឿន ហើយកើនដល់ ៧៩ក្បាល ក្នុងនោះមានមេបាចំនួន ២៦ក្បាល។ គាត់បានលក់មាន់ជាង ២០ក្បាល បានប្រាក់ប្រមាណ ៥០ម៉ឺនរៀល ហើយបានយកប្រាក់មួយផ្នែក ទៅបង់ការប្រាក់ឲ្យក្រុមរបស់គាត់ និងទិញសម្លៀកបំពាក់ និងសម្ភារសិក្សារបស់កូន។

*យោបល់ និងទស្សនៈ ក្នុងអត្ថបទនេះ ជារបស់គម្រោង និង អ្នកបញ្ចេញយោបល់ផ្ទាល់ ដូច្នេះមិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ផ្តល់ថវិកាឡើយ*